

# ឃុនស្រ៊ុន

KHUN SRUN

(១៩៤៥-១៩៧៨)

*ដោយ*

*បណ្ឌិតសភាចារ្យ* **ឃីងហុកឌី**

*ឧទ្ទិសជូនដល់វិញ្ញាណក្ខន្ធអ្នកស្នេហាអក្សរសាស្ត្រជាតិគ្រប់រូប*

*កើតនៅថ្ងៃ៣តុលា១៩៤៥នៅភូមិរវៀង, ស្រុកសំរោង, ខែត្រតាកែវ, ជាបុត្រលោកឃុនគីមឆេង (ស្លាប់ឆ្នាំ១៩៥៣) និងនាងជីអេង។ កុមារឃុនស្រ៊ុនបានចូលរៀនសាលាបឋមសិក្សានៅសាលារៀនប្រាសាទនាងខ្មៅនៅឆ្នាំ១៩៥៣។ បន្ទាប់ពីរៀនចប់នៅបឋមសិក្សាយុវជននេះបានបន្តការសិក្សានៅតាកែវក្រុងហើយបានប្រឡងចូលជាប់នៅវិទ្យាស្ថានជាតិគរុកោសល្យជានិស្សិតសាស្ត្រាចារ្យផ្នែកគណិតសាស្ត្រនៅឆ្នាំ១៩៦៤ក្នុងក្រុងភ្នំពេញ។ លោក*

បានរៀនចប់ប្រឡងចេញពីវិទ្យាស្ថានគរុកោសល្យហើយបាន ប្រឡងជាប់ចូលសាលាគរុវិជ្ជាជាន់ខ្ពស់។ ទន្ទឹមនឹងការសិក្សានៅសាលាគរុវិជ្ជាជាន់ខ្ពស់នេះលោកបានបញ្ចប់បរិញ្ញាប័ត្រអក្សរសាស្ត្រនិងមនុស្សសាស្ត្រផ្នែកអក្សរសាស្ត្រខ្មែរ[1] នៅឆ្នាំ១៩៦៩។ លោកទទួលតំណែងដំបូងជាសាស្ត្រាចារ្យមធ្យមសិក្សាបឋមភូមិនាពេលចេញពីវិទ្យាស្ថានជាតិគរុកោសល្យ។ បន្ទាប់មកបានឡើងជាសាស្ត្រាចារ្យមធ្យមសិក្សាទុតិយភូមិក្រោយបានបរិញ្ញាប័ត្រ ហើយនិងបានបញ្ចប់ការសិក្សានៅសាលាគរុវិជ្ជាជាន់ខ្ពស់។ ក្រោយមកសាស្ត្រាចារ្យអ៊ុយវន្ធថុន ប្រធានគណៈកម្មការគណិតសាស្ត្រនៃខេមរយានកម្មសិក្សាបានសុំ ក្រសួងសិក្សាធិការឲ្យផ្លាស់លោកមកជាសមាជិក ក្នុងគណៈកម្មការខេមរយានកម្ម ការបច្ចេកទេសខាងគណិតសាស្ត្រជាមួយក្រុមលោករហូតពីឆ្នាំ ១៩៧០មក។ លោកបានចូលជាសមាជិកសមាគមអ្នកនិពន្ធខ្មែរនៅថ្ងៃ១៤ធ្នូ១៩៧០។ លោកជាបុគ្គលមួយរូបស្រឡាញ់ការងារប្រកបដោយមនសិការជាតិពិតតែមិនមែនកុម្មុយនិស្តម៉ាក្ស-ឡេនីននិងម៉ៅនិយមទេតែលោកជាអ្នកស្រឡាញ់យុត្តិធម៌សង្គម ប៉ុណ្ណោះពោលគឺលោកជាអ្នកស្នេហាជាតិនិយម (Patriote)។ លោក

---

[1] យុនស្រ៊ុន ជាមិត្តរួមជំនាន់ជាមួយខ្ញុំនៅសាលាគរុវិជ្ជាជាន់ខ្ពស់និងមហាវិទ្យាល័យអក្សរសាស្ត្រនិងមនុស្សសាស្ត្រ។ ខ្ញុំចងក្រងប្រវត្តិសង្ខេប យុនស្រ៊ុននេះដោយមានចេតនាចង់រក្សាទុកជាអនុស្សាវរីយ៍ដែលយើងស្គាល់គ្នាដោយមានមិត្តភាពមេត្រីភាពនិងគ្នា ហើយនិងចង់ទុកជាឯកសារប្រវត្តិសាស្ត្រតូចមួយក្នុងចំណោមប្រវត្តិសាស្ត្រជាតិធំសម្រាប់ជនានុជនជំនាន់ក្រោយយល់ដឹងផងដែរ។ល។

បានចូលព្រៃជាមួយអ្នកតស៊ូខ្មែរនាដើមឆ្នាំ១៩៧៣ ហើយបានត្រូវខ្មែរក្រហមសម្លាប់នៅវាលឆ្នាំ១៩៧៨មុនពេលកងកម្លាំងទ័ពយៀកណាមចូលមកធ្វើអន្តរាគមន៍នៅកម្ពុជា។

លោកបានទុកស្នាដៃនានាមួយចំនួនមុននឹងចូលព្រៃ៖

-តំហើញជី១,ភ្នំពេញ, ១៩៧០។

-តំហើញជី២,ភ្នំពេញ, ១៩៧០។

-តំហើញជី៣,ភ្នំពេញ, ១៩៧០។

-សំរស់ជីវិតឬសៀវភៅតំហើញ, បោះពុម្ពសារជាថ្មីកែសម្រួលបន្ថយនិងបន្ថែម ការផ្សាយរបស់ស្នេរ, ភ្នំពេញ,១៩៧១ (ការផ្សាយជាថ្មីវិញទៀតដោយគីនប៊ុនថន, ភ្នំពេញ, ១៩៩៥) ។

-លំនៅចុងក្រោយ,ភ្នំពេញ, ១៩៧២។[2]

-ផងផាប់ចោល,ភ្នំពេញ, ១៩៧៣។[3]

-សហការជាមួយអ៊ឹង យ៉េង, កាព្យសាស្ត្រ, រៀបរៀងដោយអ៊ឹងយ៉េង ពិនិត្យសំរួលដោយ ឃុនស្រ៊ុន, ភ្នំពេញ, បោះនៅរោងពុម្ព មាយើង, ១៩៧២, ១៣៣ ទំព័រ។

---

[2] សៀវភៅនេះបានបកប្រែជាភាសាជប៉ុនដោយសាស្ត្រាចារ្យ តូម៉ូកូ អូកាដា (Tomoko OKADA)ក្នុងកម្រងប្រលោមលោកសម័យខ្មាតខ្ជីខ្មែរ, តូក្យូ, ២០០១។

[3] សម្រង់អត្ថបទក្នុងសៀវភៅនេះបានបកប្រែជាភាសាបារាំងដោយ គ្រីស្តុហ្វ ម៉ាកកេ Christophe MACQUET, « Un homme en examen » In : *Europe, revue littéraire mensuelle : Robert Walser, Ecrivains de Birmanie & du Cambodge*, Paris, 2003, pp. 250-255.

-គណិតសាស្ត្រ ថ្នាក់ ទី៨-៧-៦-៥-៤-៣ (ធ្វើជាមួយគណៈកម្មការបច្ចេកទេសខាងគណិតសាស្ត្រ នៃខេមរយានកម្មសិក្សា ដែលមានលោក អ៊ុយវន្ធថុន ជាប្រធាន)។

យុនស្រ៊ុនបានសរសេរជីវប្រវត្តិសង្ខេបផ្ទាល់ក្នុងសៀវភៅ ជនជាប់ចោទ៖

## សំរែកអ្នកសរសេរ

ខ្ញុំឈ្មោះ យុន ស្រ៊ុន កើតឆ្នាំ ១៩៤៥ នៅឃុំរវៀង ស្រុកសំរោង (តាកែវ) ជាកូនលោក យុន គីមឆេង(ស្លាប់ឆ្នាំ១៩៥៣)និងនាង ធី អេង ( រកស៊ីលក់ផ្សារបន្តិចបន្តួច ) បានចូលរៀនថ្នាក់ទី ១២ នៅសាលារៀនប្រាសាទនាងខ្មៅ នៅឆ្នាំ ១៩៥៣ ហើយស្រឡាញ់ការសិក្សាតាំងពីនោះមកដល់ពីឡូវ ។ ឆ្នាំ :

–១៩៥៩ ជាប់ C E P C និងចូលថ្នាក់ទី ៦ នៅតាកែវក្រុង

–១៩៦៣ ជាប់ DESPC (Très Bien) និង BEPC . ហើយ
ជាប់ជាគរុសិស្ស

–១៩៦៤ ជាប់ BAC I (A.Bien) និងនិស្សិតសាស្ត្រាចារ្យ ផ្នែក
គណិត

–១៩៦៥ ជាប់ BAC II ផ្នែកគណិត (A. Bien)

–១៩៦៦ ជាប់ DPESPC (លេខ១ ) CELG ( A.Bien )
និងគរុសិស្សជាន់ខ្ពស់ (លេខ២)

–១៩៦៨ ជាប់ បរិញ្ញាប័ត្រអក្សរសាស្ត្រ (A. Bien)

–១៩៧១ ជាប់ខ្លួននៅ PS ៧ ខែ ៥ ថ្ងៃ (១កុម្ភៈ–៦ កញ្ញា)

–១៩៧២ ជាប់ CES. Psychologie (A. Bien)

*ឃុនស្រ៊ុនបានថ្លៃងឧបការគុណដល់គ្រូអាចារ្យដែលបានខំបង្ហាត់បង្រៀនលោកដូចមានចែងក្នុងសៀវភៅ***សំរស់ជីវិតបុ សៀវភៅតំហើញ***ទំព័រទី៣៖*

*« ខ្ញុំសូមផ្ញើសេចក្តីគោរពស្រឡាញ់ និងអំណរគុណយ៉ាងស្មោះចំពោះលោកគ្រូ អ្នកគ្រូ ទាំងសង្ឃ ទាំងគ្រហស្ថ ដែលបានបង្ហាញអោយខ្ញុំស្រឡាញ់មនុស្ស ស្រឡាញ់ខ្មែរ និងស្រឡាញ់សំនេរ... ជាអាទិ៍ ភិក្ខុ***ចាំង ខាត់***[4] អ្នកគ្រូ***អ៊ុង សូផាន*** លោកគ្រូ***អាំ ជួន***[5] **កយ សារុន**[6] **កោង វ៉ាង់សាក់**[7] និង **ឈូង ម៉ឹង ម៉ៅ**[8]។ »*

---

[4] *សូមអាន បណ្ឌិត* **ឃីង ហុក ឌី** *(អ្នកប្រមូលចងក្រងរៀបចំ), កម្រងសិក្សាកថាវប្បធម៌ខ្មែរ, ឧទ្ទិសប្រគេនព្រះមហាវិរិយបណ្ឌិតោ* **ចាំង ខាត់**, *ភ្នំពេញ, បណ្ណាគារអង្គរ,២០១០, ៣៦៨ទំព័រ។*

[55] *នារវាងឆ្នាំ១៩៦៦ដល់១៩៧០ មានសាស្ត្រាចារ្យ១រូបដែលបានសញ្ញាប័ត្រអនុបណ្ឌិតពីឥណ្ឌាជាព្រះសង្ឃចាកសិក្ខាបទ នាម* **អាំ សួន** *មិនមែន* **អាំ ជួន** *ទេ។ លោកបានបង្រៀនពី* ***<u>ពាក្យខ្មែរដែលខ្ចីពីពាក្យបាលីសំស្ក្រឹត</u>*** *មកប្រើក្នុងភាសាខ្មែរបច្ចុប្បន្នក្នុងកម្មវិធីវិញ្ញាបនប័ត្រឧត្តមសិក្សាវេយ្យាករណ៍និងនិរុត្តិសាស្ត្រ នៅមហាវិទ្យាល័យអក្សរសាស្ត្រនិងមនុស្សសាស្ត្រភ្នំពេញ។*

[6] **កយ សារុន** *ជាគ្រូបង្រៀន ដែលមានទេពកោសល្យក្នុងការតែងកាព្យឃ្លោង។ ស្នាដៃសំខាន់លោកគឺ កម្រងកំណាព្យ* **បុប្ផាខ្មៅ** *ពណ៌នាពីបញ្ហាសង្គមជំនាន់នោះដែលបាននាំឲ្យលោកមានឈ្មោះល្បីនាទសវត្សរ៍១៩៦០។*

[7] *សូមអានបណ្ឌិតសភាចារ្យ* **ឃីង ហុក ឌី**, *លោកគ្រូធំ* **កោង វ៉ាង់សាក់**, *ភ្នំពេញ, គ្រឹះស្ថានបោះពុម្ពផ្សាយ អង្គរ, ២០១៦, ១០៥ទំព័រ។ សមូហកម្មអក្សរសាស្ត្រខ្មែរ, ឧទ្ទិសជូនសាស្ត្រាចារ្យ* **កោង វ៉ាង់សាក់**, *ប្រមូលផ្តុំអត្ថបទ ដោយ* **ឃីង ហុក ឌី**, *ភ្នំពេញ, បណ្ណាគារអង្គរ, ២០០៦,២១០ទំព័រ។*

*យុនស្រ៊ុនបានសរសេរសំបុត្រមួយទៅលោកគ្រូ កេងវ៉ាន់សាក់ចុះផ្សាយក្នុងសៀវភៅ* សំរស់ជីវិតឬសៀវភៅតំហើញ *ទំព័រ៦៩៖*

[88] *សូមអាន* Dr. KHING Hoc Dy, *L'enseignement primaire au Cambodge depuis le protectorat français jusqu'en 1975*, Phnom Penh, Ed. Angkor, 2014 (« Chhuk Meng Mao », pp. 28-30).

សំបុត្រផ្ញើជូនលោកគ្រូ **កេងវ៉ាន់សាក**



**សូមជំរាបគោរពលោកគ្រូ**

ម្ភៃឆ្នាំហើយដែលលោកគ្រូបានបង្រៀន និង ស្រាវជ្រាវអក្សរសាស្ត្រជាតិ ប្រសិនបើគិតទល់ពេលលោកគ្រូឈប់បង្រៀននាឆ្នាំ ១៩៦៨ ។ លោកគ្រូបានបង្កើតសាលាគរុវិជ្ជាមហាវិទ្យាល័យអក្សរសាស្ត្រ អង្គុលីលេខជាតិ ព្រមទាំងគំនិតជាតិនិយមក្នុងភាសា អក្សរ វេយ្យាករណ៍ វប្បធម៌ អរិយធម៌ និងក្នុងន័យចំណេះដឹងទៃទៀតយ៉ាងច្រើន ។ ខេមរយានកម្មសិក្សាជាផ្លែផ្កាមួយនៃកិរិតនោះ ។ ក្រៅពីគំនិតសមហេតុផល ត្រិះរិះពិចារណា ពិតនិយម ការនិយម និងខ្មែរនិយម ក្រៅពីជាបណ្ឌិត ជាទស្សនៈវិទូ . . . លោកគ្រូជាកវីដ៏ល្បីក្នុងសម័យទំនើប យើងមិនមែនតែគុកកាមកិលេស និង ចិត្តក្រមុំទេ ដែលពិរោះប្លែកនោះ . . . គ្រប់សំនៀវ សំដី លោកគ្រូមានសូរសំលេង និង ចង្វាក់ទាក់ទាញអ្នកផងតែម្ដង តាមនិស្ស័យសិល្បៈពីកំនើតផ្ទាល់របស់លោកគ្រូ ។

សូមលោកគ្រូទទួលពាក្យកោតស្ញើចសរសើររបស់ខ្ញុំបាទចំពោះលោកគ្រូតាមរយៈកូនសៀវភៅនេះ ដែលសំរេចរូបរាងដោយសារការខំបណ្ដុះមួយភាគដែររបស់លោកគ្រូ ។

ភ្នំពេញ, ឆ្នាំ ១៩៧០ និង ១៩៧១ ។

**យុន ស្រ៊ុន**

-៦៥-

*យុនស្រ៊ុនបានទទួលលិខិត គាមទ្រ និងសរសើរពីលោក*

**ឈូកាមុឺជ័ម៉ៅ** « *អគ្គស្នងការយុវជន* » *ជាភាសាបារាំងចុះផ្សាយ*

ក្នុងសៀវភៅ **ជនជាប់ចោទ** ទំព័រទី៨និង៩ដូចបង្ហាញដោយរូបថតខាងក្រោមនេះ៖

«J'apprécie beaucoup le caractère sérieux que M. KHUN SRUN met toujours dans tout ce qu'il entre. prend . Malgré son jeune âge l'intéressé s'est déjà fait connaître parmi le public intellectuel avec ses écrits. Il a eu le courage de défendre ses opinions en toutes circonstances .

La plupart des faits q'il relate dans ses écrits il les a vécus . Il est surtout très sensible à tout ce qui touche la condition humaine . Les malheurs des autres ne l'ont jamais laissé indifférent . Son sens social est élevé .

Il s'est toujours ouvert à moi quand il s'est trouvé devant un dilemne , quand il éprouvait des doutes . Il a fait siennes la plupart de mes propres expériences . Nous échangeons constamment nos idées sur l'avenir de notre société , sur l'améliora-tion qu'il y a à apporter , sur notre entité natio-nale sur l'avenir du monde . . . Dans tout cela son esprit reste toujours disponible . »

Phnom Penh, le 22 Févier 1972
CHHUK MENG MAO
Commissaire général à la jeunesse

*សាស្ត្រាចារ្យទាំង៣ រូបខាងលើនេះមានឥទ្ធិពលខ្លាំងក្លាក្នុងការអប់រំមនោគមវិជ្ជា ខ្មែរនិយម, ជាតិនិយម, ព្រលឹងខ្មែរ ពោលគឺឲ្យលោកមានមនសិការស្នេហាជាតិ[9], ស្អាតស្អំ គិតប្រយោជន៍រួមនៅក្នុងលក្ខណៈខ្មែរសុទ្ធសាធ។ល។*

*ពេលលោករត់ចូលព្រៃកូនស្រីនាម***ខេម***នៅតូចនៅឡើយដូចមានរូបថតខាងក្រោមនេះ៖*

---

[9] *សិស្សលោក***ឈូកាម៉ឺង់ម៉ៅ***ម្នាក់ដែលបានជ្រួតជ្រាប ដោយ មនោគមវិជ្ជា* **ព្រលឹងខ្មែរ** *បានរត់ចូលព្រៃអស់១រយៈពេលហើយក៏ត្រឡប់មកភ្នំពេញវិញដោយលែងមានជំនឿលើខ្មែរក្រហមដែលប្រកាន់មនោគមវិជ្ជាបរទេសមាន ម៉ាក្ស-ឡេនីន-ម៉ៅនិយមជាដើម ដែលមិនមែនមនោគមខ្មែរហើយលោកបានសរសេរសៀវភៅ១បង្ហាញពីការពិតដោយបានរស់នៅក្នុងព្រៃផ្ទាល់។ សូមអាន* **អ៊ិតសារិន, ស្រណោះព្រលឹងខ្មែរ**! *ភ្នំពេញ,១៩៧៤,៨០ទំព័រ។*



*រូប* **ឃុន ស្រ៊ុន** *និងភរិយាព្រមទាំងកូនថតមុនចូលព្រៃ។*



*រូបថតដែលរក្សាទុកដោយកូនស្រីលោកបង្ហាញនាពេលបង្រុំកូល*



*អាពាហពិពាហមង្គលការ(១៩៧១)ប្អូនប្រុសលោកនាម***ឃុនង៉ែត***(សព្វថ្ងៃជាវេជ្ជបណ្ឌិតនៅភ្នំពេញ) ជាមួយមិត្តនារីលោកនាម* **ស៊ីមចាន់យ៉ា** *(ជាសាស្ត្រាចារ្យទុតិយភូមិ រួមជំនាន់)។*

# ឧបសម្ព័ន្ធក្របសៀវភៅខ្លះៗ
# របស់ ឃុន ស្រ៊ុន៖












អត្ថបទដកស្រង់ពីសៀវភៅលំនៅចុងក្រោយ
បកប្រែជាភាសាជប៉ុនដោយសាស្ត្រាចារ្យ តូមូកូ អូកាដា។







អ្នករៀបរៀង អ៊ុំ យ៉េង
អ្នកកែសំរួល យុន ស្រ៊ុន

កាព្យសាស្ត្រខ្មែរ

- កំណាព្យជាអ្វី?
- លក្ខណៈទូទៅនៃកំណាព្យ
- ក្បួនតែងបទផ្សេងៗ
- កំណាព្យល្អៗ

សំរាប់កម្មវិធីសិក្សាគ្រប់ថ្នាក់
នៃ មធ្យមសិក្សា

នៅឆ្នាំ២០១៦នេះ ជនជាតិបារាំងម្នាក់ឈ្មោះ Eric GALMARD បានថតខ្សែភាពយន្ត១មានចំណងជើង ថា « ផ្នូរសម្រាប់ឃុនស្រ៊ុន »

Un tombeau pour Khun Srun (voir le video ci-dessous).

2015 Un tombeau pour Khun Srun on Vimeo

▸ 2:59

*vimeo.com › dora films › Videos*

24 mai 2016

Khem se confronte à la mémoire de son père, **Khun Srun**, écrivain cambodgien, entré dans le maquis des Khmers

# 2015 Un tombeau pour Khun Srun

de dora filmsPlusIl y a 5 mois

Khem se confronte à la mémoire de son père, Khun Srun, écrivain cambodgien, entré dans le maquis des Khmers rouges en 1973 et exécuté par eux en 1978. Elle rencontre des survivants, une cousine, une tante, des ouvriers d'un atelier des chemins de fer… En même temps, vivant dans un ancien bastion khmer rouge, elle fait face aux difficultés d'une vie précaire. En regard du parcours de Khem, le film nous fait entendre la voix autobiographique et satirique de cet écrivain humaniste et pacifiste qui a choisi pour son malheur le camp révolutionnaire. S'inscrivant dans le présent d'un pays qui se développe à grande vitesse au détriment de toute une partie des Cambodgiens, la voix de Khun Srun questionne ce Cambodge contemporain qu'il n'a pas connu. Un film d'Eric Galmard.

https://vimeo.com/167857079



2015 Un tombeau pour Khun Srun-HD.mp4